AZCambodia.com  ABCCambodia.com  AngkorDaily.com  AngkorPost.com  AngkorLink.com

# តម្រាចេកមាស




+ការរៀបអាពាហ៍ពិពាហ៍រវាងគូរស្វាមីភរិយា មាតាបិតាគប្បីជ្រើសរើស ថ្ងៃ ខែ ឆ្នាំ និងពេលវេលាល្អដើម្បីឱ្យបុត្រ និងបុត្រធីតារបស់ខ្លួនរួមរស់នៅជាមួយគ្នាបានសុខសាន្ត មូលផ្តុំទៅដោយទ្រព្យសម្បត្តិដ៏ត្រជាក់ត្រជុំ ។

តម្រាចេកមាសនេះចាស់បុរាណច្រើននិយាយរាប់មើលជោគជតារាសី គូរស្វាមីភរិយាបំរុងរៀប ការ ។ របៀបមើលសូមពិនិត្យខាងក្រោមនេះ :

+បើប្រុសឱ្យរាប់ពីលេខ១ទៅលេខ២ រៀងរហូតដល់លេខ៨ ទើសតែគ្រប់អាយុរបស់ខ្លួន ។

+ឯស្រីឱ្យរាប់ពីលេខ១ទៅលេខ៨ រាប់បញ្ច្រាសរហូតទើសតែគ្រប់អាយុរបស់ខ្លួន ។ បើត្រូវត្រង់លេខណាមួយ ឱ្យមើលតាមទំនាយខាងក្រោមនេះ :

១-បើត្រូវត្រង់លេខ១ និង លេខ២ ទំនាយថាមិនល្អឡើយ រួមរស់នៅជាមួយគ្នាមិនបានខុសច្រើនលេចឮពាក្យសម្តីឈ្លោះប្រកែកគ្នា មើលបំណាំគ្នាទៅវិញទៅមក ។

២-បើត្រូវត្រង់លេខ២-៤ ទំនាយទាយថាល្អណាស់ អាចរើសយកជាពេលវេលារៀបអាពាហ៍ពិ ពាហ៍បានរួមរស់នៅជាមួយគ្នានឹងបានសុខសាន្ត មូលផ្តុំទ្រព្យសម្បត្តិ មានជោគរាសីគ្រប់ប្រការ ។

៣-បើត្រូវត្រង់លេខ៣-៧ ទំនាយទាយថា បានរួមរស់នៅសុខសាន្តតែមុនដំបូង លុះចុងក្រោយត្រូវវិនាសព្រាត់ចាកគ្នា ។

AZCambodia.com  ABCCambodia.com  AngkorDaily.com  AngkorPost.com  AngkorLink.com

៤-បើត្រូវត្រង់លេខ ៦ ឬលេខ៨ ទំនាយទាយថាល្អប្រសើរ បុរស-ស្ត្រីណារៀបអាពាហ៍ពិពាហ៍លើលេខនេះនឹងបានសេចក្តីសុខ ចំរុងចំរើន សំបូរទៅដោយទ្រព្យសម្បត្តិ គួរជាទីរាប់អាននៃអ្នកផងទាំងពួង ។

៥-បើត្រូវត្រង់លេខ ៥ ទំនាយទាយថា បើនឹងល្អ គឺទ្រូវល្អខ្លាំង តែបើអាក្រក់វិញ គឺអាក្រក់ ណាស់។